# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៥៣

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងបានបន្តស្តាប់សក្ខីកម្មរបស់សាក្សី ស្តីពីផ្នែកជំនុំជម្រះពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១។ លោក **ប្រាក់ ខន** គឺជាសាក្សីដំបូងគេក្នុងសប្តាហ៍នេះ និងបានបញ្ចប់ការផ្តល់សក្ខីកម្មរបស់គាត់ដែលបានចាប់ផ្តើមកាលពីសប្តាហ៍មុនកន្លងទៅ ស្តីពីតួនាទីរបស់គាត់ដែលដើមឡើយធ្វើជាឆ្មាំយាម និងក្រោយមកបានក្លាយជាអ្នកសួរចម្លើយអ្នកទោសនៅមន្ទីរ ស-២១។ សាក្សីបន្ទាប់ គឺលោក **ម៉ាក់ ធីម** បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអំឡុងពេលដែលគាត់នៅធ្វើជាពេទ្យព្យាបាលមានវ័យជំទង់ក្នុងមន្ទីរ ស-២១។ គាត់បានរៀបរាប់ពីស្ថានភាពទូទៅរបស់គុក ការផ្តល់ការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការប្រព្រឹត្តមកលើអ្នកទោសស្ត្រីជាដើម។ លោក **ហ៊ីម ហុយ** គឺជាសាក្សីចុងក្រោយនាសប្តាហ៍នេះ បានបង្ហាញខ្លួននៅសវនាការ និងបានផ្តល់សក្ខីកម្មស្តីពីតួនាទីរបស់គាត់ទាំងនៅក្នុងមន្ទីរ ស-២១ និងនៅជើងឯក។ លោក **ហ៊ីម ហុយ** ត្រូវបានសាក្សីដទៃទៀតក្នុងសំណុំរឿង០០២ វគ្គ២ ដដែលនេះ បានឆ្លើយប្រាប់ពីអត្តសញ្ញាណរបស់គាត់ដែលជាឆ្មាំយាមជាន់ខ្ពស់ក្នុងមន្ទីរ ស-២១ ទោះបីជានាសប្តាហ៍នេះ គាត់បានបដិសេធចំពោះការកាន់តួនាទីទទួលខុសត្រូវដ៏សំខាន់នេះក៏ដោយ។[1] សក្ខីកម្មដែលបានផ្តល់ដោយសាក្សីទាំងបីរូបនាសប្តាហ៍នេះ ក៏ធ្លាប់ជាផ្នែកមួយដ៏សំខាន់ក្នុងសំណុំរឿង០០១ ផងដែរ ហើយសាក្សីទាំងបីរូបនេះ បានបង្ហាញខ្លួនដោយមានជំនួយពីមេធាវីប្រឹក្សា។[2] បន្ថែមពីលើការស្តាប់សក្ខីកម្មរបស់សាក្សីទាំងបីរូបនេះ អង្គជំនុំជម្រះសាលាដំបូងក៏បានធ្វើការដោះស្រាយផងដែរ ជុំវិញសំណើសុំឲ្យមានការផ្អាកកិច្ចដំណើរការនីតិវិធីសវនាការ មុនការបង្ហាញខ្លួនរបស់សាក្សីពីររូបចុងក្រោយ ក្នុងផ្នែកជំនុំជម្រះស្តីពីមន្ទីរ

សន្តិសុខ ស-២១ និងបានដោះស្រាយនូវបញ្ហាផ្លូវច្បាប់នានា ពាក់ព័ន្ធនឹងភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម និងសិទ្ធិរបស់សាក្សីប្រឆាំងនឹងការឆ្លើយដាក់ពិរុទ្ធភាពមកលើខ្លួនឯងផងដែរ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ លេណា ហារីស ពោមីរ៉យ (Lena Harris-Pomeroy), ម៉ាលេនី ហៃដ៍ (Melanie Hyde), នីកូឡាស មេយខក (Nicholas Maycock), ខេតលីន កាហ្វហ្រ្វៀ (Caitlin McCaffrie), នំ វិសុទ្ធ, តាយ លីណា និង ធន ស្ថាពរ ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

---

[1] សាក្សីលោក **ប្រាក់ ខន** និងលោក **តយ តេង** បានឆ្លើយដោយឡែកដាច់ពីគ្នា ប្រាប់ពីអត្តសញ្ញាណរបស់លោក **ហ៊ឹម ហុយ** ថាជាអ្នកមើលការខុសត្រូវឆ្មាំយាមនៅខាងក្រៅបរិវេណមន្ទីរ ស-២១ និងដឹកអ្នកទោសពីមន្ទីរ ស-២១ ទៅកាន់ជើងឯក ផងដែរ *សូមមើល* របាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមក្នុងសំណុំរឿង០០២ វគ្គ២ លេខ ៥២ ស្តីពីសវនាការលើភស្តុតាងសប្តាហ៍ទី៤៩ (ចុះថ្ងៃទី២៥ ដល់ទី២៨ ខែមេសា ឆ្នាំ២០១៦)។

[2] សាក្សីលោក **ប្រាក់ ខន** និងលោក **ហ៊ឹម ហុយ** ធ្លាប់បានបង្ហាញខ្លួនមកផ្តល់សក្ខីកម្មក្នុងសវនាការ ក្នុងសំណុំរឿង០០១ រីឯកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃបទសម្ភាស៍របស់លោក **ម៉ក់ ធីម** ក៏ត្រូវបានអានឡើងវិញដាក់ក្នុងកំណត់ហេតុផងដែរ។ សំណុំរឿង០០១ គឺជាការជំនុំជម្រះក្តីលើលោក **កាំង ហ្គេចអ៊ាវ** ហៅ **ឌុច** ដែលជាប្រធានមន្ទីរ ស-២១ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថា **ឌុច** មានពិរុទ្ធភាពនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ហើយបានកាត់ទោស **ឌុច** ដាក់ពន្ធធនាគារ ៣៥ឆ្នាំ (*សូមមើល* "សាលក្រម" របស់អង្គជំនុំជម្រះសាលាដំបូង (ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០) លេខ E188)។ លោក **កាំង ហ្គេចអ៊ាវ** បានប្តឹងសាទុក្ខលើសាលក្រមនេះទៅអង្គជំនុំជម្រះតុលាការកំពូល ក៏ប៉ុន្តែត្រូវបានបដិសេធចោល។ ការិយាល័យសហព្រះរាជអាជ្ញា ក៏បានធ្វើបណ្តឹងសាទុក្ខផងដែរ ហើយកាលពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយបានបង្កើនការដាក់ពន្ធធនាគារជនជាប់ចោទរហូតដល់អស់មួយជីវិត *សូមមើល* "សាលដីកា" របស់អង្គជំនុំជម្រះតុលាការកំពូល (ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២) លេខ F28 ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University